**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
~~~***~~~

សាលាដំបូងខេត្តកណ្ដាល
សាលក្រមព្រហ្មទណ្ឌលេខៈ **០៣២(ឆ)**
ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ឋានៈចៅក្រម ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា
លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**មេធាវី**

លោក [redacted] និងលោកស្រី [redacted] មេធាវីការពារក្ដីឲ្យជនជាប់ចោទ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៣១៩ អ.ក ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៨ ដែលមានជនជាប់ចោទៈ

១.ឈ្មោះ [redacted] ក្រូច ភេទប្រុស អាយុ ៣១ឆ្នាំ ជាជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] រឿន (ស) ម្ដាយឈ្មោះ [redacted] ម៉ាន (រ) ប្រពន្ធឈ្មោះ [redacted] ចាន់ថុល មានកូន ០២ នាក់ ទោសពីមុន ជាប់ពន្ធនាគារ ០៦ ខែ (ប្រើប្រាស់គ្រឿងញៀន) ។ (**ក្នុងឃុំថ្ងៃខែឆ្នាំ ១៧ /០៧/២០១៩**)

២.ឈ្មោះ [redacted] **យ៉ា** ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ថុន (រ) ម្ដាយឈ្មោះ [redacted] ថា (រ) នៅលីវ ទោសពីមុនគ្មាន ។ (**ក្នុងឃុំថ្ងៃខែឆ្នាំ ១៧ /០៧/២០១៩**)

៣.ឈ្មោះ [redacted] **ម៉ៅ** ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ថុន (រ) ម្ដាយឈ្មោះ [redacted] ថា (រ) នៅលីវ ទោសពីមុនគ្មាន ។ (**គេចខ្លួន**)

ពីបទៈ **លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់អាវុធ) , កាន់កាប់អាវុធ , ធ្វើចរាចរណ៍អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ និងសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់អាវុធ)** ប្រព្រឹត្តនៅភូមិ



Scanned with CamScanner
~~~

វែង ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ , ៣៥៧ , ៤៨៨ ,២៩ នៃក្រមព្រហ្មទណ្ឌ ។

## ដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោង ១៧ និង ៣០នាទី មានករណីលួចមានស្ថានទម្ងន់ទោស , កាន់កាប់អាវុធ , ធ្វើចរាចរណ៍អាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ និងសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស កើតឡើងនៅចំណុចភូមិវែង ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល បង្កឡើងដោយឈ្មោះ [redacted] ក្រូច , ឈ្មោះ [redacted] យ៉ា និងឈ្មោះ [redacted] ម៉ៅ ដែលជាមុខសញ្ញាប្លន់បានសម្រេចជាច្រើនកន្លែង ។ លុះមកដល់ថ្ងៃកើតហេតុជនទាំងបីនាក់ខាងលើបានចេញធ្វើសកម្មភាពប្លន់នៅចំណុចគោលដៅខាងលើ តែត្រូវបានសមត្ថកិច្ចស្រាវជ្រាវដេញតាមទាន់ធ្វើការឃាត់ខ្លួនបាន និងដកហូតអាវុធខ្លីម៉ាក CF៩៨-៩ បញ្ជូនមកអធិការដ្ឋាននគរបាលស្រុកអង្គស្នួលតែម្តង ហើយអាវុធខ្លីនេះគឺជនជាប់ចោទបានទិញពីឈ្មោះ ល័ក្ខ ដែលកំពុងជាប់ពន្ធនាគារព្រៃស ។

## បានឃើញ

-ដីកាសន្និដ្ឋានស្ថាពរលេខៈ ៧៦៣ ដកសព ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-ដីកាដំណោះស្រាយលេខៈ ៨២៤/១៩ ដកជស ចុះថ្ងៃទី ០៤ខែ កញ្ញា ឆ្នាំ ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ។

-ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះបន្តលេខៈ ៨៨៩ ដកចត/១៩ ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០១៩ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

## នាពេលសវនាការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ការសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

## សំអាងហេតុ

១-កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅភូមិវែង ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល ពិតជាកើតមាននូវអំពើ លួចមានស្ថានទម្ងន់ទោស ប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ក្រូច , ឈ្មោះ [redacted] យ៉ា និងឈ្មោះ [redacted] ម៉ៅ បានធ្វើសកម្មភាពលួច ម៉ូតូ ដោយបានប្រើប្រាស់នូវអាវុធជាតិផ្ទុះ និងបានកាន់កាប់អាវុធដោយខុសច្បាប់ ហើយបានធ្វើចរាចរណ៍អាវុធគ្រឿងផ្ទុះ ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ក្រូច បានឆ្លើយនាពេលសវនាការថា៖ នៅថ្ងៃកើតហេតុសមត្ថកិច្ចបានទៅដល់ផ្ទះរបស់ខ្លួន ហើយបានឆែកឆេរនៅកន្លែងដេករបស់ខ្លួន រកឃើញអាវុធម៉ាក ឡុត (F ៩៨.៩) មួយដើម និងអាវុធកែច្នៃចំនួន ០៣ ដើមវែង ។ អាវុធមានឡុកនេះខ្លួនបានទិញពីគេក្នុងតម្លៃ ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ។ ចំណែកអាវុធកែច្នៃ ០៣ ដើមវែងនេះ ខ្លួនបានដូរគ្រឿងញៀនពីក្មេងប្រុសមិនស្គាល់ឈ្មោះរស់នៅក្នុងភូមិជាមួយខ្លួន ។ ចំណែកម៉ូតូម៉ាកស៊ីរ៉ុស គឺខ្លួនជាអ្នកកាន់កាប់ បន្ទាប់មកម្ចាស់គេបានរក



Scanned with CamScanner

ឃើញ ហើយខ្លួនបានសន្យាប្រគល់ម៉ូតូសងគេវិញ តែដល់ថ្ងៃសន្យាខ្លួនពុំបានប្រគល់ឲ្យទាន់ពេលវេលា ក្រោយមកម្ចាស់គេក៏ប្ដឹងប៉ូលីសតែម្ដង ។ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **យ៉ា** បានឆ្លើយនាពេលសវនាការថា ៖ នៅថ្ងៃកើតហេតុ ខ្លួនបានជិះម៉ូតូយកបបរទៅផ្ទះ [redacted] ក្រូច រួចហើយខ្លួនក៏ជិះត្រឡប់មកវិញ ស្រាប់មានមនុស្សប្រុសម្នាក់បានកាក់ម៉ូតូខ្លួន ហើយសួរថាមានឃើញ កែវ ក្រូច នៅផ្ទះទេ ខ្លួនឆ្លើយថានៅ ហើយសមត្ថកិច្ចក៏បានចូលទៅផ្ទះឈ្មោះនេះ ពេលនោះខ្លួនក៏ជិះម៉ូតូគេចចេញ ។ លុះព្រឹកឡើង ខ្លួនកំពុងអង្គុយមើលគេជីកស៊ីនៅផ្ទះឈ្មោះ រើន ស្រាប់តែមានសមត្ថកិច្ចចុះមកឃាត់ខ្លួន និងឆែកឆេរនៅលើខ្លួនរកឃើញថ្នាំញៀនចំនួន ០១ កញ្ចប់តូច ។ ចំពោះម៉ូតូម៉ាក ស៊ីរូង គេបានយកមកបញ្ចាំប្អូនថ្លៃរបស់ឈ្មោះ [redacted] ក្រូច សព្វថ្ងៃនេះប្អូនថ្លៃរបស់ឈ្មោះ [redacted] ក្រូច បានជាប់ពន្ធនាគារហើយ ម៉ូតូនោះក៏ប្រគល់ឲ្យទៅឈ្មោះ [redacted] ក្រូច ហើយឈ្មោះនេះបានឲ្យបន្តទៅឈ្មោះ [redacted] ម៉ៅ ។ ឃើញថា ចម្លើយនេះអាចឲ្យតុលាការជឿបាន ព្រោះថា ចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគបាលយុត្តិធម៌ ។

៣-ទាំងចម្លើយរបស់ជនជាប់ចោទ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌មានភាពស៊ីសង្វាក់គ្នា ដែលកំណត់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែន។

៤-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ប្រាកដមែន។

៥-អំពើរបស់ជនជាប់ចោទបានស្តែងឡើងដោយ មានចេតនាយកទ្រព្យរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធផ្ទាល់ខ្លួន និងបានកាន់កាប់ប្រើប្រាស់អាវុធដោយខុសច្បាប់ ដែលអំពើនេះច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ និងមានចែងក្នុងមាត្រា៣៥៣ , មាត្រា៣៥៧ , មាត្រា៤៨៨ , មាត្រា២៩ នៃក្រមព្រហ្មទណ្ឌ ។

៦-ជនជាប់ចោទជានីតិជន ហើយបានប្រព្រឹត្តអំពើល្មើសដោយមានចេតនា និងការយល់ដឹងពីអំពើរបស់ខ្លួន ដូច្នេះជននេះត្រូវទទួលខុសត្រូវនូវទង្វើដែលខ្លួនបានប្រព្រឹត្តចំពោះច្បាប់។

៧-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ក្រូច** ,ឈ្មោះ [redacted] **យ៉ា** និងឈ្មោះ [redacted] **ម៉ៅ** ដែលមានសារតាជាតិខាងលើ ពីបទៈ លួចមានស្ថានទម្ងន់ទោស , កាន់កាប់អាវុធ , ធ្វើចរាចរណ៍អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ និងសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិវែង ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ , មាត្រា៣៥៧ , មាត្រា៤៨៨ , មាត្រា២៩ នៃក្រមព្រហ្មទណ្ឌ ។

៨-គប្បីតុលាការប្រកាសទណ្ឌកម្មលើជនជាប់ចោទក្នុងកំរិតដាក់ពន្ធនាគារ ៤ឆ្នាំ ដោយពិចារណាទៅលើភាពធ្ងន់ស្រាលនៃបទល្មើស និងសកម្មភាពល្មើសរបស់ជនជាប់ចោទដូចខាងក្រោមៈ

+អំពើល្មើសរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់ ទ្រព្យសម្បត្តិរបស់អ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ។

+សកម្មភាពល្មើសពុំបណ្តាលឲ្យមានព្យសនៈកម្មធ្ងន់ធ្ងរឡើយ ។

+ជនជាប់ចោទបានឆ្លើយសារភាព ។ មូលហេតុទាំងនេះនាំឲ្យតុលាការ ពិចារណាប្រកាសទោសក្នុងកំរិតខាងលើដល់ជនជាប់ចោទ។

៩-តាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៨ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល វត្ថុតាងចាប់យកមាន៖

+កាំភ្លើងវែងកែច្នៃចំនួន ០៣ ដើម បាញ់គ្រាប់កង់។

+កាំភ្លើងវែងចំនួន ០១ ដើម ម៉ាក CKC (គ្មានលេខ)។

+គ្រាប់កាំភ្លើងចំនួន ០៧ ។



Scanned with CamScanner

+គ្រាប់កាំកង់ចំនួន ២៦ គ្រាប់ ។

+សំបកគ្រាប់កាំភ្លើងវែងចំនួន ០១ គ្រាប់។

+ខោអាវប៉ាវ៉ាចំនួន ០១ កំផ្លេរ ។ គប្បីសម្រេចរឹបអូស ។

១០-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំៈ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ ឃើញថាជនជាប់ចោទបានឆ្លើយសារភាព ។ ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ ។ រក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ៧៦៣ ដកសព ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។ ស្នើរសុំឲ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទតាមច្បាប់ ។ តុលាការយល់ស្របចំពោះសេចក្តីសន្និដ្ឋាននេះ ។

១១-មេធាវីការពារក្តីឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថាៈ ក្រោយពីបានសួរដេញដោលនាពេលសវនាការ ជនជាប់ចោទបានទទួលស្គាល់តែការកាន់កាប់អាវុធដោយខុសច្បាប់តែប៉ុណ្ណោះ ហើយចម្លើយជនជាប់ចោទដែលឆ្លើយ មានភាពស៊ីសង្វាក់គ្នា ។ ដូច្នេះស្នើរសុំឲ្យតុលាការលើកលែងចោទប្រកាន់លើជនជាប់ចោទពីបទលួចមានស្ថានទម្ងន់ទោស ។ តុលាការឃើញថាសេចក្តីសន្និដ្ឋាននេះមានលក្ខណៈត្រឹមត្រូវមួយចំនួនពាក់ពាន់ទៅនឹងអង្គហេតុនិងអង្គច្បាប់ តែការស្នើរសុំឲ្យតុលាការលើកលែងចោទប្រកាន់លើជនជាប់ចោទ ពីបទលួចមានស្ថានទម្ងន់ទោស នោះ ឃើញថា ពុំមានសំអាងហេតុគ្រប់គ្រាន់ក្នុងការដោះបន្ទុកលើជនជាប់ចោទឡើយ ។

## សម្រេច

១.ផ្តន្ទាទោសលើៈ

ក.ឈ្មោះ [redacted] ក្រូច ភេទប្រុស អាយុ ៣១ឆ្នាំ ជាជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] រឿន (ស) ម្តាយឈ្មោះ [redacted] ម៉ាន (រ) ប្រពន្ធឈ្មោះ [redacted] ចាន់ថុល មានកូន ០២ នាក់ ទោសពីមុន ជាប់ពន្ធនាគារ ០៦ ខែ (ប្រើប្រាស់គ្រឿងញៀន) ។ (ក្នុងឃុំថ្ងៃខែឆ្នាំ ១៧ /០៧/២០១៩)

ខ.ឈ្មោះ [redacted] យ៉ា ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ថុន (រ) ម្តាយឈ្មោះ [redacted] ថា (រ) នៅលីវ ទោសពីមុនគ្មាន ។ (ក្នុងឃុំថ្ងៃខែឆ្នាំ ១៧ /០៧/២០១៩)

គ.ឈ្មោះ [redacted] ម៉ៅ ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ថុន (រ) ម្តាយឈ្មោះ [redacted] ថា (រ) នៅលីវ ទោសពីមុនគ្មាន ។ (គេចខ្លួន)

*ដាក់ពន្ធនាគាក្នុងម្នាក់ៗកំណត់រយៈពេល ៤(បួន)ឆ្នាំ* ពីបទៈ លួចមានស្ថានទម្ងន់ទោស , កាន់កាប់អាវុធ , ធ្វើចរាចរណ៍អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ និងសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិវែង ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ , មាត្រា៣៥៧ , មាត្រា៤៨៨ ,មាត្រា២៩ នៃក្រមព្រហ្មទណ្ឌ ។

២.វត្ថុតាងរួមមានៈ

+កាំភ្លើងវែងកែច្នៃចំនួន ០៣ ដើម បាញ់គ្រាប់កង់។

+កាំភ្លើងវែងចំនួន ០១ ដើម ម៉ាក CKC (គ្មានលេខ)។



Scanned with CamScanner

+គ្រាប់កាំភ្លើងចំនួន ០៧ ។

+គ្រាប់កាំកង់ចំនួន ២៦ គ្រាប់ ។

+សំបកគ្រាប់កាំភ្លើងវែងចំនួន ០១ គ្រាប់។

+ខោអាវប៉ារ៉ាចំនួន ០១ កំផ្លេរ ។

<u>ត្រូវរឹបអូស ។</u>

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ក្រូច និងឈ្មោះ [redacted] យ៉ា និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ម៉ៅ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | |

បានចម្លងត្រឹមត្រូវតាមច្បាប់

ថ្ងៃពុធ ១០រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅកណ្តាល, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]